# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ អធិប្បាយអំពីពាក្យថាព្រះព្រហ្មលិខិត

Website: www.hoksavann.org

ថ្ងៃទី៨ មករា ២០០៥

ពាក្យថា<ព្រហ្មលិខិត> មានដើមកំណើតពីភាសាបាលីដែលចែកជាពីរបទ គឺ<ព្រហ្ម> និង<លិខិត> ។ ពាក្យថា <ព្រហ្ម> គឺជាឈ្មោះអាទិទេពមួយព្រះអង្គនៅក្នុងសាសនាព្រាហ្មណ៍ គឺព្រះព្រហ្ម។ ពាក្យថា<លិខិត> ប្រែថាការចារឬការសរសេរ ។ រួមពាក្យទាំងពីរ <ព្រហ្មលិខិត> ប្រែថាការចារឬការសរសេររបស់ព្រះព្រហ្ម ។ គេយល់ថា សេចក្ដីសុខទុក្ខចំរើនវិនាសរបស់មនុស្សកើតមកពីព្រះព្រហ្ម បណ្ដាលឲ្យកើតឡើង ។ ទស្សនៈនេះប្រដៀងគ្នានឹងទស្សនៈរបស់ហោរាសាស្ត្រ ដែលហៅថា<ព្រហ្មជាតិ> ដែលទស្សន៍ទាយថា ជោគជតារាសីរបស់មនុស្សកើតមកអំពីព្រហ្មលិខិត ឲ្យផលបែបណាតាមតែថ្ងៃខែកំណើតរបស់ខ្លួន ។ បើអ្នកទាយនោះជាអ្នកកាន់ព្រះពុទ្ធសាសនា ក៏ទាញមករកពុទ្ធសាសនាថា បណ្ដាលមកពីកម្មផល ។ មនុស្សបានអាយុប៉ុន្មានស្លាប់ទៅវិញ ក៏ដោយសារព្រះព្រហ្មលោកដាក់កម្រិតមក ។ អ្នកនេះនិងនាងនេះបានជាគូនឹងគ្នា ដោយសារព្រះព្រហ្មលោកតម្រូវឲ្យ ។ បានសេចក្ដីថា ព្រះព្រហ្មជាអ្នកគូសវាសនាល្អអាក្រក់ឲ្យមនុស្ស ។ តាមន័យនេះហើយ បានជាមានបទចម្រៀងខ្មែរខ្លះ ច្រើនបន្ទោសទៅលើព្រះព្រហ្ម ថាពុំគួរក៏រឹតខ្លួនឲ្យមានទុក្ខដូច្នេះសោះ ។

ព្រះពុទ្ធសាសនាវិញ ព្រហ្មលិខិតបានដល់កម្មផលរបស់ខ្លួនវិញទេ ។ សេចក្ដីសុខទុក្ខចំរើនវិនាស បណ្ដាលមកពីកម្មផលរបស់ខ្លួន កម្មស្សកោម្ហិ ។ បើមានសេចក្ដីទុក្ខ គប្បីបន្ទោសឬសោកស្ដាយនូវអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តវិញ ។ បើខ្លាចសេចក្ដីទុក្ខ ត្រូវជៀសវាងអំពើអាក្រក់ កុំធ្វើតទៅទៀត មុននឹងបន្ទោសកម្មពីអតីត: គប្បីពិនិត្យមើលសកម្មភាពល្អអាក្រក់របស់ខ្លួនក្នុងបច្ចុប្បន្ន ព្រោះជួនកាលផលអាក្រក់ដែលខ្លួនបានទទួលពេលនេះ កើតមកអំពីអំពើអាក្រក់របស់ខ្លួនក្នុងបច្ចុប្បន្ននេះឯង ។ ពុទ្ធសាសនាសំដែងថា បើមានសេចក្ដីទុក្ខណាមួយកើតឡើង ត្រូវដោះស្រាយមូលហេតុដែលនាំឲ្យកើតទុក្ខនោះ សេចក្ដីទុក្ខក៏ត្រូវរលត់ ។ ប៉ុន្តែមានសេចក្ដីទុក្ខខ្លះពុំអាចដោះស្រាយបាន ត្រូវតែលះបង់ បើពុំដូច្នោះទេនឹងខូចផ្លូវចិត្ត ដូចជាសមាជិកគ្រួសារណាម្នាក់បានស្លាប់ ដែលពុំអាចរស់ឡើងវិញបាន ។

ពុទ្ធសាសនិកជនខ្មែរគោរពព្រះពុទ្ធសាសនា ដូច្នេះការសរសេរការនិយាយស្ដី ត្រូវពោលឲ្យត្រឹមត្រូវ តាមខ្លឹមសាររបស់ព្រះពុទ្ធសាសនា គឺព្រះពុទ្ធសាសនាពោលថា ហេតុយ៉ាងណាផលយ៉ាងនោះ ឬកម្មយ៉ាងណាផលយ៉ាងនោះ ពុំមែនព្រះព្រហ្មលិខិតឡើយ ។ គេតែងឮបទចម្រៀង និងអ្នកនិយាយក្នុងរឿងល្ខោនខ្មែរថា អ្វីទាំងអស់កើតមកពីព្រហ្មលិខិតគឺពុំអាចជៀសព្រហ្មលិខិតបានឡើយ ។ ត្រង់នេះធ្វើឲ្យអ្នកស្ដាប់ដែលជាពុទ្ធសាសនិកជនស្ដាប់ទៅទាស់ត្រចៀក ព្រោះពុទ្ធសាសនានិយាយពីកម្មលិខិត គឺកម្មរបស់ខ្លួនវាចារ ឬដាក់ក៏រឹតឲ្យខ្លួនតាមអំពើរបស់ខ្លួន ។ ជោគវាសនាល្អអាក្រក់យ៉ាងណា គឺបណ្ដាលមកពីកម្មទាយាទោ គឺកម្មជាមត៌ករបស់ខ្លួនពីអតីត:និងបច្ចុប្បន្ន ពុំមែនកើតពីព្រះជាម្ចាស់អង្គណាមួយឡើយ ។ ដូច្នេះអ្នកនិពន្ធខ្មែរសរសេរឬនិយាយរឿងល្ខោនក្ដី អ្នកតែងបទចំរៀងក្ដី ត្រូវប្រើពាក្យកម្មលិខិតជាន័យព្រះពុទ្ធសាសនា មិនត្រូវប្រើពាក្យព្រហ្មលិខិត ដែលជាព្រហ្មញ្ញសាសនាឡើយ ។៚